- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ម.ព.ក.ម.** ហើយកំណត់វិធានការកែតម្រូវដើម្បីអនុវត្ត ។

មាត្រា៩.-

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា១០.-

១០.១. ក្រុមប្រឹក្សាភិបាលនៃ ម.ព.ក.ជ. ត្រូវធ្វើការប្រជុំយ៉ាងតិច ៣ (បី)ខែម្ដង តាមគំនិតផ្ដួចផ្ដើម និងការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំរបស់នាយកនៃ ម.ព.ក.ជ. ។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ)រូបដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច១០(ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានចំនួនសមាជិកលើសពី ៥០ (ហាសិប) ភាគរយនៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្ដងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានកូរ៉ុមគ្រប់ចំនួនឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្ដមានុភាព។

១០.៣. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ ម.ព.ក.ជ. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

១០.៤. ម.ព.ក.ជ. ត្រូវផ្ញើជូនទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ៖

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ ម.ព.ក.ជ.
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្ដីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

១០.៥. ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនហួសពី ១៥ [illegible]

ផ្នែកទី២

អង្គភាពប្រតិបត្តិរបស់ ម.ព.ក.ជ.

មាត្រា១១.-

ម.ព.ក.ជ. ត្រូវគ្រប់គ្រងដោយនាយកមន្ទីរពេទ្យមួយរូបដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកមន្ទីរពេទ្យរូបនេះមានតួនាទីជានាយកប្រតិបត្តិ។

មាត្រា១២.-

១២.១. នាយកនៃ **ម.ព.ក.ជ.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ព.ក.ជ.** មានភារកិច្ចៈ

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ព.ក.ជ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ព.ក.ជ.** ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ព.ក.ជ.**ដែលក្រុមប្រឹក្សាភិបាលកំណត់តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

១២.២. នាយកនៃ **ម.ព.ក.ជ.** ជាតំណាងរបស់មន្ទីរពេទ្យ ក្នុងការទាក់ទងជាមួយតតិយជន។

១២.៣. នាយកនៃ **ម.ព.ក.ជ.**ត្រូវស្នើទៅក្រសួងសុខាភិបាលសុំតែងតាំងនាយករង មួយរូប ឬច្រើនរូបជាជំនួយការ តាមភាពចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយកនិងនាយករងត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

ផ្នែកទី៣

បុគ្គលិករបស់ ម.ព.ក.ជ.

មាត្រា១៣.-

១៣.១. បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ព.ក.ជ.** មានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាល ឬមកពីក្រសួងស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ [illegible] ប្រាក់កម្រៃផ្សេងៗ ដែលកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

១៣.២. ម.ព.ក.ជ. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ ។

១៣.៣. បុគ្គលិក ម.ព.ក.ជ. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ជានេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ ។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ប្រាក់កម្រៃ លើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

ផ្នែកទី៤

ទ្រព្យសម្បត្តិរបស់ ម.ព.ក.ជ.

មាត្រា១៤.-

១៤.១. ម.ព.ក.ជ. ទទួលជាដើមទុនដំបូងពីរដ្ឋនូវដីធ្លី និងអចលនវត្ថុដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមាន ៤២ ៨២៨ (សែសិបពីរពាន់ ប្រាំបីរយម្ភៃប្រាំបី) ម៉ែត្រក្រឡាស្ថិតនៅដីឡូត៍លេខ១០០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

១៤.២. ម.ព.ក.ជ. អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការមន្ទីរពេទ្យបាន ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន ។

ផ្នែកទី៥

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ព.ក.ជ.

មាត្រា១៥.-

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ព.ក.ជ. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

មាត្រា១៦.-

១៦.១. នាយករបស់ ម.ព.ក.ជ. ជាអាណាប័កដើមខ្សែរបស់មន្ទីរពេទ្យហើយត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

១៦.២. អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវ[illegible] បាន ដោយមានការព្រមព្រៀងពីគណនេយ្យករ ម.ព.ក.ជ. ។

មាត្រា១៧.-

១៧.១. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ព.ភ.៤.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។ គណនេយ្យករ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក **ម.ព.ភ.៤.** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសំឡេងឆ្នោតឡើយ ។

១៧.២. គណនេយ្យករមានភារកិច្ចៈ

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សា និងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ **ម.ព.ភ.៤.**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣. គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាណាព្យាបាលរបស់ខ្លួន ។

មាត្រា១៨.-

១៨.១. ប្រភពធនធានរបស់ **ម.ព.ភ.៤.** រួមមានៈ

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ព.ភ.៤.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធនដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ព.ភ.៤.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ម.ព.ភ.៤.**
- ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗដោយ **ម.ព.ភ.៤.**
- កម្រៃនៃទ្រព្យរបស់ **ម.ព.ភ.៤.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលត្រូវបានទទួលអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលត្រូវបានប្រគល់ឱ្យ **ម.ព.ភ.៤.** ។

១៨.២. ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ម.ព.ភ.៤.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ ។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ព.ភ.៤.** ត្រូវកំណត់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣. ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ម.ព.គ.ខ. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ។

១៨.៤. អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ នៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង ម.ព.គ.ខ. ជាបន្ទុកនៃថវិការដ្ឋ។

១៨.៥. ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឱ្យ ម.ព.គ.ខ. ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹក និងថ្លៃភ្លើង។

១៨.៦. សោហ៊ុយវិភាគ និងសោហ៊ុយដំណើរការ សម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង ម.ព.គ.ខ. ដែលមានបញ្ជាក់ចំណែកដែលភាគីម្ខាងៗត្រូវរ៉ាប់រង។

មាត្រា១៩.-

១៩.១. ការងារគណនេយ្យរបស់ ម.ព.គ.ខ. រួមមាន៖

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារនិងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ ម.ព.គ.ខ. ត្រូវ៖

- ស្របតាមវិធានការដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ ម.ព.គ.ខ. ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.២. របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ព.គ.ខ. ត្រូវរៀបចំដោយគណនេយ្យករនិងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

មាត្រា២០.-

មូលនិធិរបស់ ម.ព.គ.ខ.គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅអគ្គនាយកដ្ឋានរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៦

របបសារពើពន្ធរបស់ ម.ព.គ.ខ.

មាត្រា២១.-

លើកលែងតែមានបដិប្បញ្ញត្តិដែលមានចែងដោយច្បាប់ ម.ព.គ.ខ. ត្រូវស្ថិតនៅ[illegible]សារពើពន្ធ។

ផ្នែកទី៧

លទ្ធកម្មរបស់ ម.ព.ក.ជ.

មាត្រា២២.-

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ព.ក.ជ.** ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ដែលពាក់ព័ន្ធនឹងកិច្ចការនេះ ។

ជំពូកទី៣

អាណាព្យាបាលភាព

ផ្នែកទី១

អាណាព្យាបាលបច្ចេកទេស

មាត្រា២៣.-

២៣.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.ក.ជ.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល ២(ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារ ដែលបានបញ្ជូនដោយនាយកនៃ **ម.ព.ក.ជ.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២. លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាងត្រូវផ្ញើជូនទៅនាយកនៃ **ម.ព.ក.ជ.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកនៃ **ម.ព.ក.ជ.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាទទួលបានការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាល ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍនៃ **ម.ព.ក.ជ.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា២៤.-

២៤.១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារដែលត្រូវបានបញ្ជូន [illegible] ចែង ក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល [illegible]

គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

២៤.២. នាយកនៃ ម.ព.ភ.ជ. ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងវិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

មាត្រា២៥.-

២៥.១. រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ ម.ព.ភ.ជ. ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់មន្ទីរពេទ្យ
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់ របស់ក្រុមប្រឹក្សាភិបាល។

២៥.២. ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកនៃ ម.ព.ភ.ជ. ហើយនាយកនៃ ម.ព.ភ.ជ. ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

មាត្រា២៦.-

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់ ម.ព.ភ.ជ. ក្នុងករណីយល់ថា ជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី២

របបគណនេយ្យនិងហិរញ្ញវត្ថុ

មាត្រា២៧.-

២៧.១. ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ ម.ព.ភ.ជ. ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល១ (មួយ)ខែចាប់ពីថ្ងៃទទួល

ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរយៈពេល ២ (ពីរ)ខែ ចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយនាយកនៃ ម.ព.ស.ជ.ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៧.២. លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើជូនទៅនាយកនៃ ម.ព.ស.ជ. ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនៃ ម.ព.ស.ជ. ត្រូវបញ្ជូនព័ត៌មាននេះ ទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានឆ្លើយតប ក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

មាត្រា២៨.-

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ ម.ព.ស.ជ. ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន៖

- សេចក្តីសម្រេចស្តីពីការលើកលែងគណនេយ្យដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ
- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្តីសម្រេចនេះ ត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មាត្រា២៩.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១ (មួយ)រូប ប្រចាំ ម.ព.ស.ជ.។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ម.ព.ស.ជ.ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

មាត្រា៣០.-

៣០.១. ការគ្រប់គ្រងដោយអាណាប័កដើមខ្សែនៃ ម.ព.ស.ជ. ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.២. ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់[illegible] អគ្គនាយកដ្ឋានរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួង[illegible]

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ ម.ធ.គ.ថ. នៅពេលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៣១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ដើម្បីសូមចុះហត្ថលេខា
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខងារ នាយទាហាន
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **ជុំ សោភ័ណ្ឌ** អត្តលេខ ០១០៩៥៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២-ឧត្តមសេនីយ៍ត្រី **ទាន់ សារ៉ាន់** អត្តលេខ ០០០៧៨៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន ៤៩ គ្រឿង ជូនសាស្ត្រាចារ្យ វេជ្ជបណ្ឌិតស៊ីវិល ដែលមានស្នាដៃល្អក្នុងការបង្ហាត់បង្រៀនដល់ សិស្ស និស្សិត នៅវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ សម្រេចទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ÷

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ និចមិន្ទ :

១-ឯកឧត្តមសាស្ត្រាចារ្យ	ញ៉ា	ឈួយ	អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល
២-លោកជំទាវសាស្ត្រាចារ្យ	តាន់	ធូចឆេង	អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល
៣-ឯកឧត្តម	អ៊ុំ	សុផល	សាកលវិទ្យាធិការ សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល
៤-លោកសាស្ត្រាចារ្យ	យក់	សុខដាន់ណារា	សាកលវិទ្យាធិការរង សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល
៥-លោកសាស្ត្រាចារ្យ	គា	ស៊ីនប៊ុណ្ណារ៉ាត	សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
៦-លោកសាស្ត្រាចារ្យ	ស៊ុំ	ភាណណាល់	មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
៧-លោកសាស្ត្រាចារ្យ	ម៉ូ	ម៉ាច	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៨-លោកសាស្ត្រាចារ្យ	ឈូ	អ៊ីម៉េង	មន្ទីរពេទ្យកុមារជាតិ
៩-លោកសាស្ត្រាចារ្យ	ភាំង	សី	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
១០-លោកសាស្ត្រាចារ្យ	ជួង	ភារិទ្ធ	មហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល
១១-លោកសាស្ត្រាចារ្យ	ទ្រាក់	សេងឃួរ	មន្ទីរពេទ្យព្រះកុសុមៈ
១២-លោកសាស្ត្រាចារ្យ	គេង	សៀន	មន្ទីរពេទ្យព្រះកុសុមៈ
១៣-លោកសាស្ត្រាចារ្យ	ឈៀង	ចំនួរិទ្ធ	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
១៤-លោកសាស្ត្រាចារ្យ	ឃាង	យ៉ាណា	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
១៥-លោកវេជ្ជបណ្ឌិត	សាយ	សេងលី	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
១៦-លោកសាស្ត្រាចារ្យ	សំ	សោភាន់	ទីប្រឹក្សា វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ
១៧-លោកវេជ្ជបណ្ឌិត	ស្ដើង	ចាវ	ទីប្រឹក្សា វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ
១៨-លោកវេជ្ជបណ្ឌិត	អ៊ុង	សំអាន	វិទ្យាស្ថានស្រាវជ្រាវសុខភាពសាធារណៈ
១៩-លោកវេជ្ជបណ្ឌិត	ឈូ	ឈីយាង	មន្ទីរពេទ្យព្រះអង្គឌួង

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ៖

១-លោកសាស្ត្រាចារ្យ	ង៉ោ	ឃួង	មន្ទីរពេទ្យព្រះអង្គឌួង
២-លោកសាស្ត្រាចារ្យ	ឡឹ	ធីវៈ	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
៣-លោកវេជ្ជបណ្ឌិត	ឡៅ	ស៊ុនថាវរ៉េត	មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
៤-លោកវេជ្ជបណ្ឌិត	មាស	អេដា	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
៥-លោកវេជ្ជបណ្ឌិត	អ៊ុម	ចាម	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
៦-លោកវេជ្ជបណ្ឌិត	ស៊ិន	ផ្កាឡា	មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
៧-លោកវេជ្ជបណ្ឌិត	ម៉ុន	មុត	មន្ទីរពេទ្យព្រះកុសុមៈ
៨-លោកវេជ្ជបណ្ឌិត	កេត	ឈីស៊ុថា	មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
៩-លោកវេជ្ជបណ្ឌិត	គ្លាន់	យុគន្ធា	មន្ទីរពេទ្យកុមារជាតិ
១០-លោកវេជ្ជបណ្ឌិត	ឃិត	ស៊ុនណារ៉ា	មន្ទីរពេទ្យគន្ធបុប្ផា
១១-លោកវេជ្ជបណ្ឌិត	នាក់	មករា	សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល
១២-លោកវេជ្ជបណ្ឌិត	ខៃ	គា	មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺកាមរោគ-អេដស៍-សើស្បែក

១៣-លោកវេជ្ជបណ្ឌិត យិត ស៊ុនណារ៉ុង មន្ទីរពេទ្យកាល់ម៉ែត្រ

១៤-លោកវេជ្ជបណ្ឌិត ស្រ៊ូ យ៉ីណា មន្ទីរពេទ្យកុមារជាតិ

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោកវេជ្ជបណ្ឌិត ជុំ ណារុន មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

២-លោកវេជ្ជបណ្ឌិត ឈី ជាតិតា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៣-លោកវេជ្ជបណ្ឌិត កែន ម៉េងអ៊ាង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៤-លោកវេជ្ជបណ្ឌិត មាន់ ស៊ីម៉ាន់ថា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៥-លោកវេជ្ជបណ្ឌិត ម៉ាន់ ម៉ុម មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៦-លោកវេជ្ជបណ្ឌិត កៅ ម៉ុនឡៀង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៧-លោកវេជ្ជបណ្ឌិត មោខ តិម មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

៨-លោកវេជ្ជបណ្ឌិត អ៊ី សុរិយាតា មជ្ឈមណ្ឌលគាំពារមាតា និងទារក

៩-លោកវេជ្ជបណ្ឌិត សុខ ម៉ាង មន្ទីរពេទ្យព្រះកុសុមៈ

១០-លោកវេជ្ជបណ្ឌិត ស៊ិន សម្ផា មន្ទីរពេទ្យព្រះកុសុមៈ

១១-លោកវេជ្ជបណ្ឌិត គីម សុខមុល មន្ទីរពេទ្យព្រះកុសុមៈ

១២-លោកវេជ្ជបណ្ឌិត គូ គីមសៀក មន្ទីរពេទ្យព្រះកុសុមៈ

១៣-លោកវេជ្ជបណ្ឌិត សុខ ឈីម មន្ទីរពេទ្យគន្ធបុប្ផា

១៤-លោកវេជ្ជបណ្ឌិត មាន់ សារី មន្ទីរពេទ្យគន្ធបុប្ផា

១៥-លោកវេជ្ជបណ្ឌិត ម៉ាច គីមឆេង មន្ទីរពេទ្យកុមារជាតិ

១៦-លោកវេជ្ជបណ្ឌិត ជា ចន្ទ្ធារិទ្ធ មន្ទីរពេទ្យព្រះសីហនុ នៃក្ដីសង្ឃឹម

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៥៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនសប្បុរសជនចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តឧត្តមមានជ័យ** ស្ថិតនៅក្នុងឃុំទំពែរមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានរាយនាមដូចខាងក្រោម :

១-លោកស្រី	**ទាវ សុខអេង**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៥០.៣០០ ដុល្លារ
២-លោក	**ឡុង ហេង**	សប្បុរសជននៅខេត្តកំពង់ស្ពឺ	ថវិកាចំនួន ៥០.២៥០ ដុល្លារ
៣-លោក	**ម៉ែន ម៉ារីន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៥០.២០០ ដុល្លារ
៤-លោក	**ម៉ែន មុំយ**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៥០.២០០ ដុល្លារ

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៣៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តឧត្តមមានជ័យ** ស្ថិតនៅក្នុងឃុំទំព័រមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានរាយព្រះនាម-និងនាមដូចខាងក្រោម :

ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ផ្តល់ជូន :

១-លោកស្រី **ទាន់ សុខជា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.១៧០ ដុល្លារ

២-លោកស្រី **ទាន់ សុខុមាវី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.១០០ ដុល្លារ

៣-លោក **ឈុន គឹមឡេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០៥០ ដុល្លារ

៤-លោក **ម៉េង ឈុន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០២៩ ដុល្លារ

ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណ **ស៊ូ សុខជា** ចៅអធិការវត្តឧត្តមមានជ័យ បច្ច័យចំនួន ៥.១៨០ ដុល្លារ

២-លោក **កុយ ស៊ុំ** សប្បុរសជននៅកំពង់ស្ពឺ ថវិកាចំនួន ៥.១០០ ដុល្លារ

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនលោកសាស្ត្រាចារ្យ និងនាយនគរបាល ចំនួន១៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-លោក បណ្ឌិត ឡុយ រាជ៊ី
២-លោក បណ្ឌិត សុត គន្ធី
៣-លោក បណ្ឌិត ថែម ឃួត
៤-លោក បណ្ឌិត គង់ សុវណ្ណារ៉ា
៥-លោក បណ្ឌិត ចំរួន តារាស្មើ
៦-លោក គង់ ប៊ុនធី
៧-លោក ទូច ស៊ីយមោច
៨-លោក ឡុច សារិន

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក អាត់ មន្ថា
២-លោក គង់ ឃន់
៣-លោក ឡាច មន្ថា
៤-លោក ឈួន សុផុន
៥-លោក ទេត សុវណ្ណ
៦-វរសេនីយ៍ឯក ម៉ិន សុវណ្ណា

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែមករា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានចំពាក់ មេដាយមាសការងារ ជូនលោកសាស្ត្រាចារ្យ និងនាយឧត្តមសេនីយ៍ ចំនួន០៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-កញ្ញា ទាត់ ឡេងចាន់ធាយ៉ា

២-កញ្ញា ឡេង ស៊ុនសោភ្ជារី

៣-លោក សាន សុផន

៤-លោក ស៊ាង ធញ្ញា

៥-លោក ផន សុខឃុយ

៦-អនុសេនីយ៍ឯក សំ សម្បត្តិ

៧-អនុសេនីយ៍ឯក ឃឹម ខន

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤០.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងនិងអភិវឌ្ឍន៍សមិទ្ធផលនានា នៅខេត្តកោះកុង និងកំពង់ចាម ដូចមាននាមខាងក្រោម :-

ក.មេដាយប្រាក់ស្ថាបនាជាតិ :

១ វរសេនីយ៍ទោ **ខៀន សុភ័ក្រ** ០៣៣៧៩៣ នាយលេខាធិការរង កងពលតូចអន្តរាគមន៍ លេខ១៤ ជួយអភិវឌ្ឍន៍ កងពលតូចអន្តរាគមន៍លេខ១៤ អស់ថវិកាចំនួន ៨.៤៥០ ដុល្លារ

២ វរសេនីយ៍ទោ **ម៉ៅ ធារិទ្ធ** ០០១៣៥១ នាយរងការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងគោកជួយកសាង សមិទ្ធផលនានា ក្នុងវត្តជម្ពូរាម ស្រុកព្រៃឈរ ខេត្តកំពង់ចាម ថវិកា ចំនួន ៧.៧៥០ ដុល្លារ

ខ.មេដាយសំរឹទ្ធស្ថាបនាជាតិ :

១ វរសេនីយ៍ត្រី **ឌេន ឌី** ០៩៣០៩៥ កងអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជួយកសាងសាលប្រជុំតំបន់ប្រតិបត្តិការសឹករង កោះកុង ថវិកា ចំនួន ១.១០០ ដុល្លារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ចំនួន១០រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាងនិងអភិវឌ្ឍន៍ទីបញ្ជាការកងការពារព្រំដែន លេខ៥០១ កន្លងមក ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ និបទិន្ន :

១	លោក	**សេក តេះ**	ប្រធានការិយាល័យ នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ
២	លោក	**ស្រ៊ុន អន្តរេន**	ប្រធានការិយាល័យ នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ
៣	លោក	**គង់ សុខមាន**	ប្រធានការិយាល័យ នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ
៤	លោក	**អ៊ឹម សក្ខិណា**	ប្រធានការិយាល័យ នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ
៥	វរសេនីយ៍ឯក	**កែវ សេខលន**	០២៦ ៨៤៥ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ
៦	វរសេនីយ៍ទោ	**កែវ អនុជ**	០២១៦៥២ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ប៉ៃលិន

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ :

១	លោក	**សេក សារឹម**	មន្ត្រី នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ
២	លោក	**ព្រាប មុនិន្ទ**	មន្ត្រី នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ

៣ លោក **សួន សុចិន្តា** មន្ត្រី នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ

៤ លោក **ឈឹម ចិន្តុល** មន្ត្រី នាយកដ្ឋាន សេវាកម្ម សហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយទិញដី ចាក់ដី ចំនួន ០៣ហិតា សាងសង់អគារសិក្សា ០២ខ្នង កំពស់០២ជាន់ មាន២០បន្ទប់ អគារទីចាត់ការ សាលប្រជុំ របង ខ្លោងទ្វារ បំពាក់សម្ភារៈសិក្សា នៅសាលារៀនខ្មែរ-ចិន ចុងវា ឃុំឫស្សីក្រោក និង ជួយកសាងប្រាង្គ ០១កន្លែង នៅវត្តអម្ពវនារាម បឹងត្រាវ ឃុំបត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោក	ទៅ	ជីសុខ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣៥.០០០ ដុល្លារ
២-អ្នកស្រី	ឈឿង	ឃួចចាន់	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២០.០០០ ដុល្លារ
៣-លោក	ទៅ	គីមចាន់	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ៣០.០០០ ដុល្លារ
៤-អ្នកស្រី	អាន់	សៅយ៉ាន់	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១១.៨០០ ដុល្លារ
៥-លោក	ឈុយ	មុំឆួន	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.៨០០ ដុល្លារ
៦-អ្នកស្រី	អាន់	មុំឡាង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.២០០ ដុល្លារ
៧-លោក	ទៅ	ជួយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៥.០០០ ដុល្លារ
៨-លោក	ទៅ	មុនហុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១២.០០០ ដុល្លារ
៩-លោក	តាំង	គីមឆួយ	សប្បុរសជននៅស្រុកមង្គលបុរី	ថវិកាចំនួន ១០.២៣០ ដុល្លារ
១០-លោក	លី	សុខលាយ	សប្បុរសជននៅស្រុកមង្គលបុរី	ថវិកាចំនួន ១០.១៨០ ដុល្លារ
១១-លោក	ទៅ	ចាន់	សប្បុរសជននៅស្រុកមង្គលបុរី	ថវិកាចំនួន ១០.០៧០ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	តេង	ហ្វាងជិញ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៨.០០០ ដុល្លារ
២-លោក	ចៅ	ជីហ្វួយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៦.៥០០ ដុល្លារ
៣-លោក	ចៅ	ស៊ុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៦.០០០ ដុល្លារ
៤-លោក	ចៅ	ម៉ិញ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៦.០០០ ដុល្លារ
៥-លោក	ម៉ិញ	ជីតង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.២០០ ដុល្លារ
៦-លោក	ឡី	ហាន់ជុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.១០០ ដុល្លារ
៧-លោក	ឈឹម	តៅហុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.០០០ ដុល្លារ
៨-លោក	យ៉ាំ	គាតឈេង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.០០០ ដុល្លារ
៩-លោក	ជិង	សៀង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥.០០០ ដុល្លារ

គ.មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក	យ៉ាំ	ជប់មី	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.៥០០ ដុល្លារ
២-លោក	ចៅ	គាត់ឈួន	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.០០០ ដុល្លារ
៣-លោក	ចៅ	ជីឃៀន	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.០០០ ដុល្លារ
៤-លោក	ជា	គួងជី	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៧០០ ដុល្លារ
៥-លោក	ជា	គាងឈួង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៧០០ ដុល្លារ
៦-លោក	សូច	យុគសេង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៧០០ ដុល្លារ
៧-លោក	ចៅ	ហួយម៉ិញ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៥០០ ដុល្លារ
៨-លោក	តាំង	អេកគួង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៤០០ ដុល្លារ
៩-លោក	ជា	គាងម៉ី	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.៣០០ ដុល្លារ
១០-លោក	ខៀ	ហួយជុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.២០០ ដុល្លារ
១១-លោក	ចៅ	ជិញហួយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.០៥០ ដុល្លារ
១២-លោក	ឈី	ម៉ីជុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.០០០ ដុល្លារ
១៣-លោក	ម៉ិញ	ចាចម៉ិញ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២.០០០ ដុល្លារ
១៤-លោក	ចៅ	គាត់ចាំ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៧០០ ដុល្លារ
១៥-លោក	ជា	ឈានឡា	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៧០០ ដុល្លារ
១៦-លោក	ម៉ាង	ឈីមហួង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៧០០ ដុល្លារ
១៧-លោក	ចៅ	ហួយឡា	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៦០០ ដុល្លារ
១៨-លោក	ចៅ	គាត់ម៉ឹង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
១៩-លោក	យ៉ុី	ជី	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
២០-លោក	ម៉ិច	ម៉ីចឡាង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
២១-លោក	ចៅ	ហូអ៊ឹង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
២២-លោក	ឈី	ម៉ីតុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
២៣-លោក	ចៅ	ឡៀហ្វួយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៥០០ ដុល្លារ
២៤-លោក	ម៉ិញ	ម៉ីតោយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.៣០០ ដុល្លារ
២៥-លោក	ចង	ហាន់ជូ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.២០០ ដុល្លារ
២៦-លោក	ឃ្យាំ	ហុង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.២០០ ដុល្លារ
២៧-លោក	ឈៀង	គុតខាច	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.១០០ ដុល្លារ
២៨-លោក	ម៉ិច	គាតម៉ឹង	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
២៩-លោក	តែ	ជីម៉ាន់	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ

៣០-លោក	ឆាន់	ឆាយទួច	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣១-លោក	យ៉ាំ	ស៊ីហុិញ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣២-លោក	ចៅ	ឡៃឈុន	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៣-លោក	យ៉ាំ	គុយតុយ	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៤-លោក	ឆី	អ៊ុចម៉ុច	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៥-លោក	គួច	ស៊ុយម៉ាន់	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៦-	Cyrus	Collman	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៧-អភាជនីយដ្ឋាន	ឈូ	ឆីម៉ា	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៨-លោក	គួច	តាំចិន	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១.០០០ ដុល្លារ
៣៩-លោក	ហេង	គិមសុន	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១០.០០០ ហ្វ្រង់
៤០-លោក	ង៉ែ	អ៊ានអូ	សប្បុរសជននៅប្រទេសបារាំង	ថវិកាចំនួន ១០.០០០ ហ្វ្រង់

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរភារកិច្ច លោក ឌូ សុខអ៊ាន ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ទៅក្នុង ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងសុខាភិបាល ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុង មាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ពានជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ពានជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ១៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងឧបដ្ឋានសាលា សាលាបាលី ខ្លោងទ្វារ ជំនួរ កុដិកាវ៉ូ និងសមិទ្ធផលនានា នៅវត្តព្រៃមាស ស្ថិតនៅក្នុងឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមាសស្ពានជាតិ:

១-	លោក	នាត សុជាតិ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១០.១០០ដុល្លារ
២-	លោក	ផេង សុខ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១០.១០០ដុល្លារ
៣-	អ្នកស្រី	ចាប ស៊ីមួន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១០.១០០ដុល្លារ
៤-	អ្នកស្រី	ផេង ណេងអេង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១០.០៧០ដុល្លារ

ខ. មេដាយប្រាក់ស្ពានជាតិ:

១-	លោក	ម៉ែ មឿន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន៥.៣០០ដុល្លារ
២-	លោក	ស៊ុម ផន់	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន៥.៣០០ដុល្លារ
៣-	អ្នកស្រី	ជា ស្រួស់	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៥.២០០ដុល្លារ
៤-	លោក	សុខ ចិន្តា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៥.១០០ដុល្លារ
៥-	លោក	មួង ធុំ	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកាចំនួន៥.១០០ដុល្លារ
៦-	អ្នកស្រី	សុខ ធីតា	សប្បុរសជនខ្មែរនៅរាជធានីភ្នំពេញ	ថវិកាចំនួន៥.០៦០ដុល្លារ
៧-	លោក	វ៉េង គីម	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន៥.០៣០ដុល្លារ
៨-	លោក	អេង ម៉ុងហ៊ាង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៥.០០០ដុល្លារ

៩-	លោក	ពិន	គឹមហុង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៥.០០០ដុល្លារ
១០-	លោក	ជាម	ស៊ីតេក	សប្បុរសជននៅខេត្តកណ្ដាល	ថវិកាចំនួន៥.០០០ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជននៅក្នុង និងក្រៅ ប្រទេសចំនួន៣៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងសមិទ្ធផលផ្សេងៗជាច្រើននៅវត្តគៀរ និង វត្តពោធិប្រជុំជន ស្ថិតក្នុងឃុំព្រែករំដេង និងឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលមានរាយព្រះនាម និងនាមដូចខាង ក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ:

១-	សម្តេចព្រះវន្នរ័ត	ណយ	ជ្រឹក	គង់នៅរាជធានីភ្នំពេញ	បច្ច័យចំនួន៣៣.០០០ដុល្លារ
២-	ព្រះតេជគុណ	សា	សុខចិន	ព្រះចៅអធិការវត្តពោធិប្រជុំជន	បច្ច័យចំនួន១០.២៨០ដុល្លារ
៣-	អ្នកស្រី	ម៉ែន	ស្រីពៅ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៤២.០៥០ដុល្លារ
៤-	លោក ស៊ុន	សំណាង ហៅ	តាតិន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៣៣.៥០០ដុល្លារ
៥-	លោក	ខេង	មុនទេព	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១៥.០៨០ដុល្លារ
៦-	លោក	ជិន	ស្រ៊ាង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១៥.១៧០ដុល្លារ
៧-	ឧកញ៉ា	សំ	ចាន់ណារិទ្ធ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១៤.៣០០ដុល្លារ
៨-	ឧបាសក	ខៀវ	តឹម	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន១១.១៥០ដុល្លារ
៩-	ឧបាសក	ឈាង	ចិត	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន១១.០៥០ដុល្លារ

គ_មេដាយសំរិទ្ធស្ថាបនាជាតិ៖

១-	ឧបាសក	ស្វន	ឌុន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៤.៥៣០ដុល្លារ
២-	លោក	ជា	សុខឌី	សប្បុរសជនខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន៤.០៧០ដុល្លារ
៣-	លោក	ទោង	ឈន់ហេង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន៣.០៨៨ដុល្លារ
៤-	ឧបាសិកា	ឌូ	រី	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន៣.៨០០ដុល្លារ

មាត្រា២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦. អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

